Mouth of Duwamish Wet Weather Facilities

King County Wastewater Treatment | Combined Sewer Overflow (CSO) Control Program

សេចក្តីសង្ខេបនៃ Community Sounding Board៖ ខែតុលា ដល់ ខែធ្នូ ឆ្នាំ 2025

របាយការណ៍សង្ខេប

យើងកំពុង វិនិយោគលើវិធីសាស្ត្រថ្មីៗ ដើម្បីកាត់បន្ថយការហូរចេញនៃប្រព័ន្ធលូបង្ហូររួម។ នៅពេលមានភ្លៀងធ្លាក់ខ្លាំង បំពង់លូបង្ហូររួមនៅក្នុងទីក្រុង Seattle អាចនឹងពេញយ៉ាងរហ័សដោយសារទឹកភ្លៀង។ នៅពេលរឿងនេះកើតឡើង បំពង់លូនឹងបញ្ចេញទឹកដែលលើសទាំងនោះទៅក្នុងទន្លេ និង បឹង និងឈូងសមុទ្រ Puget Sound ដែលនៅក្បែរនោះ។ នេះហៅថា ការហៀរចេញនៃប្រព័ន្ធលូបង្ហូររួម ឬហៅកាត់ថា CSO។ CSOs ត្រូវបានរចនាឡើងកាលពីច្រើនទសវត្សរ៍មុន ដើម្បីបង្ការកុំឱ្យទឹក ហៀរត្រឡប់ចូលក្នុងផ្ទះ និងទឹកន្លែងអាជីវកម្ម នៅពេលមានព្យុះភ្លៀងធ្លាក់ខ្លាំង។

យើងក្រោងនឹងសាងសង់អាងប្រព្រឹត្តិកម្មទឹកក្នុងរដូវរស្សានៅមាត់ទន្លេ Duwamish (Mouth of Duwamish Wet Weather Facilities) ដើម្បីកែលម្អគុណភាពទឹកនៅក្នុងទន្លេ Duwamish River និងឈូងសមុទ្រ Elliott Bay។ គម្រោងនេះនឹងកាត់បន្ថយការហូរហៀរ CSOs ចេញពីបំពង់បង្ហូររួម ចំនួនប្រាំ។ នៅឆ្នាំ 2025 សមាជិកសហគមន៍បានចែករំលែកគំនិតនានា ដើម្បីចូលរួមរចនារូបរាង និងប រិយាកាសនៃសំណង់ ដែលបានស្នើឡើងទាំងនេះ។

ការសហការជាមួយ Community Sounding Board

នៅខែតុលា ឆ្នាំ 2025 យើងបានបង្កើត Community Sounding Board (Sounding Board) សម្រាប់កម្ម វិធីនេះ។ ក្រុមប្រឹក្សាផ្តល់យោបល់នេះ រួមមានសមាជិកចំនួន 10 រូប ដែលមកពីតំបន់ ភាគខាងត្បូងនៃ ទីប្រជុំជន (South of Downtown, SODO) និងសហគមន៍នៅក្បែរៗនោះ។ ចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ 2025 យើងបានរៀបចំ កិច្ចប្រជុំចំនួន 4 លើក។ សមាជិកបានផ្តល់ធាតុចូលលើរូបរាង និងបរិយាកាសនៃ សំណង់ដែលបានគ្រោងទុក នៅក្នុងតំបន់ ភាគខាងត្បូងនៃទីប្រជុំជន (South of Downtown, SODO)។

Sounding Board និងបុគ្គលិកគាំទ្រ នៅពីមុខមាត់ទន្លេ Duwamish River ក្នុងទីក្រុង Seattle។

ការជ្រើសរើស និងការសម្រាំង

យើងបានបើកទទួលពាក្យសុំចូលរួមជាសាធារណៈ នៅក្នុងខែសីហា និងខែកញ្ញា ឆ្នាំ 2025។ យើងបានផ្សព្វផ្សាយព័ត៌មានតាមរយៈ វិធីសាស្ត្រចម្រុះដូចជា៖

- សេចក្តីប្រកាសនៅលើគេហទំព័រ
- សេចក្តីជូនដំណឹងថ្មីៗតាមព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិច (E-newsletter)
- អ៊ីមែល និងការហៅទូរសព្ទ
- ការផ្ញើកាតតាមប្រៃសណីយ៍
- ខិតប័ណ្ណ
- ការធ្វើបទបង្ហាញ និងកិច្ចប្រជុំជាមួយអង្គការផ្សេក លើសហគមន៍
- សកម្មភាពចុះជួបផ្ទាល់ដោយសហការជាមួយដៃគូសហគមន៍ ដើម្បីទាក់ទងទៅកាន់អ្នកដែលកំពុងជួបប្រទះបញ្ហាស្ថានផ្ទះសម្បែង



សេចក្តីប្រកាស និងទម្រង់បែបបទដាក់ពាក្យត្រូវបានរៀបចំឡើងជាច្រើនភាសា៖

- ភាសាចិនសាមញ្ញ និងភាសាចិនបុរាណ
- ភាសាអង់គ្លេស
- ខ្មែរ
- ភាសាអេស្ប៉ាញ
- ភាសាវៀតណាម

យើងបានពិនិត្យមើលពាក្យសុំទាំងអស់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចៗគ្នា និងបានជ្រើសរើសសមាជិកចំនួន 10 រូប ដែលស្គាល់ច្បាស់ពីតំបន់ SODO និងសហគមន៍នៅក្បែរៗនោះ។ Sounding Board ក៏តំណាងឱ្យមតិយោបល់ចម្រុះ និងបទពិសោធន៍ជីវិតខុសៗគ្នាផងដែរ។

អ្វីដែលយើងបានឮ

Sounding Board បានផ្តល់មតិត្រឡប់លើលក្ខណៈពិសេសជាក់លាក់នៃការរចនា។ ប្រធានបទសំខាន់ៗរួមមាន៖

- ឆ្លុះបញ្ចាំងពីវប្បធម៌នៃតំបន់ SODO
- ប្រើប្រាស់វិធីសាស្ត្រ និងសម្ភារៈល្អៗបំផុតសម្រាប់បរិស្ថាន
- ពិចារណាលើឱកាសសម្រាប់ការបង្កើតលំហសាធារណៈសម្រាប់សហគមន៍
- ការធ្វើឱ្យលេចធ្លោនូវធម្មជាតិនៅក្នុងការរចនា
- ប្រើប្រាស់ពណ៌ស្រាល និងមានលក្ខណៈអព្យាក្រឹត

ក្រុមប្រឹក្សាផ្តល់យោបល់បានបង្កើតនូវ ផ្ទាំងរូបភាពចំនួនបី ដើម្បីចែករំលែកគំនិតរបស់ពួកគេសម្រាប់៖

- ការរៀបចំសោភ័ណភាព
- សម្ភារៈសំណង់
- ផ្លាកសញ្ញាពន្យល់ព័ត៌មាន

ចូលទៅកាន់គេហទំព័ររបស់គម្រោង ដើម្បីពិនិត្យមើលអនុសាសន៍របស់ Sounding Board សម្រាប់ការរចនាសំណង់តាមរយៈតំណភ្ជាប់ kingcounty.gov/MDWetWeatherFacilities។

ដោយផ្អែកលើមតិយោបល់របស់អ្នក

Sounding Board
នេះត្រូវបានបង្កើតឡើងដោយផ្អែកលើមតិយោបល់របស់សហគមន៍កាលពីរដូវក្តៅមុន។ ចន្លោះថ្ងៃទី 1 ខែកក្កដា ដល់ ថ្ងៃទី 31 ខែសីហា ឆ្នាំ 2025 យើងបានធ្វើការស្ទង់មតិមួយ ដើម្បីស្វែងយល់ពីមតិយោបល់អំពីថាតើរូបរាងនៃ SODO Wet Weather Treatment Station (WWTS) ដែលបានស្នើឡើងគួរតែមានលក្ខណៈបែបណា។ យើងទទួលបានការឆ្លើយតបពីអ្នកចូលរួមចំនួន 182 នាក់ និងមតិយោបល់ច្រើនជាង 500។

ការឆ្លើយតបទៅនឹងអាទិភាពរបស់សហគមន៍

យើងបានពិចារណាលើមតិយោបល់របស់សហគមន៍ មុននឹងបន្តទៅមុខទៀតជាមួយនឹងការរចនាគម្រោង។ យើងបានថ្លឹងថ្លែងរវាងអាទិភាពរបស់សហគមន៍ ជាមួយនឹងកត្តាផ្សេងៗទៀត ដូចជាតម្រូវការផ្នែកច្បាប់ និងការចំណាយ។ នេះគឺជាវិធីដែលយើងនឹងប្រើប្រាស់មតិយោបល់របស់អ្នក៖

- មតិយោបល់មួយចំនួន ដូចជា "ការប្រើប្រាស់សួនស្រូបទឹកភ្លៀង" កំពុងត្រូវបានពិចារណាថាជាការណែនាំ។
- មតិយោបល់ផ្សេងទៀត ដូចជាការផ្តល់យោបល់ឱ្យបង្កើនការដាំដើមឈើតាមរយៈ "ព្រៃខ្នាតតូច" ត្រូវបានដាក់បញ្ចូលទៅក្នុងដំណាក់កាលរចនាបច្ចុប្បន្ន ក្នុងទម្រង់ដែលបានកែសម្រួល។
- មតិយោបល់មួយចំនួននឹងត្រូវបានពិចារណានៅក្នុងដំណាក់កាលបន្តបន្ទាប់នៃគម្រោង។ យើងនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការរចនាបង់នៅឡើយ ហើយមិនទាន់ដល់ចំណុចដែល ត្រូវសម្រេចចិត្តលើរាល់ព័ត៌មានលម្អិតទាំងអស់នោះទេ ដូចជាសម្រាប់ផ្លាកសញ្ញាពន្យល់ព័ត៌មានជាដើម។
- អនុសាសន៍ទាំងអស់ទាក់ទងនឹងសិល្បៈសាធារណៈ នឹងត្រូវផ្តល់ជូនទៅកាន់ស្ថាប័ន 4Culture ដោយហេតុថាពួកគេគឺជាអ្នកគ្រប់គ្រង និងដឹកនាំលើផ្នែកនៃការរចនាមួយនេះ។
- មតិយោបល់មួយចំនួន ដូចជា "ប្រើប្រាស់ឈើដែលកែច្នៃជាផ្នែងធំៗ" គឺស្ថិតនៅក្រៅគោលដៅ និងវិសាលភាពនៃគម្រោងនេះ ដោយសារតែកត្តាដូចជា ការចំណាយ ឬរបៀបដែលស្ថានីយនេះដំណើរការ។ យើងបានកត់ត្រារាល់មតិយោបល់ទាំងអស់ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីអ្វីដែលសហគមន៍យកចិត្តទុកដាក់។

សូមអានរបាយការណ៍ពេញលេញ ដើម្បីដឹងពីព័ត៌មានលម្អិតអំពីរបៀបដែលអនុសាសន៍របស់ Sounding Board ត្រូវបានយកមកពិចារណា។

ជំហានបន្ទាប់

យើងនឹងបន្តជំរុញការរចនាទីតាំងនេះ ហើយនឹងបន្តជូនដំណឹងដល់លោកអ្នកអំពីដែនការរបស់យើង។ ធាតុចូលរបស់អ្នកមានសារៈសំខាន់ចំពោះយើងក្នុងអំឡុងពេលដំណើរការនេះ។ កម្មវិធីនេះបានផ្លាស់ប្តូរទៅជាគម្រោងចំនួនបី ហើយយើងទន្ទឹងរង់ចាំក្នុងការចែករំលែកព័ត៌មានលម្អិតបន្ថែមទៀត។

ទាក់ទងមកយើង

សូមទាក់ទង Broch Bender តាមរយៈ DWetWeaFacilities@kingcounty.gov ឬ 206-263-1189។

អំពី Mouth of Duwamish Wet Weather Facilities

King County កំពុង វិនិយោគលើវិធីសាស្ត្រថ្មីៗ ដើម្បីកាត់បន្ថយការហូរចេញនៃប្រព័ន្ធលូបង្ហូររួម។ វាជួយកាត់បន្ថយការបំពុល និងរក្សាទឹកនៅក្នុងតំបន់របស់យើងឱ្យមានភាព ស្អាត។ អាងប្រព្រឹត្តិកម្មទឹកក្នុងរដូវរស្សានៅមាត់ទន្លេ Duwamish (Mouth of Duwamish Wet Weather Facilities) នឹងកាត់បន្ថយការហូរនៃប្រព័ន្ធលូបង្ហូររួម (CSOs) ចេញពីបំពង់បង្ហូររួមចំនួនប្រាំ។ King County មានផែនការសាងសង់៖

- ស្ថានីយប្រព្រឹត្តិកម្មទឹកក្នុងរដូវរស្សាថ្មីមួយនៅក្នុងតំបន់ SODO
- អាងស្តុកទឹកក្រោមដីមួយកន្លែង នៅក្បែរតំបន់ North Delridge លើផ្លូវ West Marginal Way Southwest
- បំពង់បង្ហូរទឹកចេញថ្មី
- បំពង់ថ្មីៗ និងអគារគាំទ្រផ្សេងៗ

គម្រោងនេះនឹងអនុវត្តតាម ច្បាប់ទឹកស្អាតរបស់រដ្ឋ និងថ្នាក់ជាតិ។
ចូលទៅកាន់ kingcounty.gov/MDWetWeatherFacilities ដើម្បីស្វែងយល់បន្ថែម និងចុះឈ្មោះទទួលព័ត៌មានបច្ចុប្បន្នភាពចុងក្រោយបង្អស់។

សេវាបកប្រែផ្ទាល់មាត់ និងបកប្រែជាឯកសារ អាចរកបានសម្រាប់អ្នកដោយឥតគិតថ្លៃ។
ប្រសិនបើអ្នកត្រូវការសេវាកម្មទាំងនេះ សូមទាក់ទង DWetWeafacilities@kingcounty.gov។

Los servicios de interpretación y traducción están disponibles para usted sin costo alguno. Si los necesita, comuníquese con DWetWeafacilities@kingcounty.gov.

សេវាបកប្រែនិងបកប្រែអាចរកបានសម្រាប់អ្នកគ្មានការចំណាយ។ បើត្រូវការគេសូមទំនាក់ទំនងមកកាន់ DWetWeafacilities@kingcounty.gov។

免費為您提供口譯和筆譯服務。如果您需要這些服 務，請聯絡 DWetWeafacilities@kingcounty.gov.

免费为您提供口译和笔译服务。如果您需要这些服 务，请联络 DWetWeafacilities@kingcounty.gov.

Dịch vụ thông dịch và biên dịch được cung cấp miễn phí cho quý vị. Nếu quý vị cần những dịch vụ này, xin vui lòng liên hệ với DWetWeafacilities@kingcounty.gov.

មានជាទម្រង់ផ្សេងទៀត៖ 206-477-5371 ឬការបញ្ជូនបន្ត TTY៖ 711